PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## សម្រាប់ត្រីមាសទីបី នៃឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់

## នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២

PESTECH

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទីបី ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ២៤៨ ០១៣ | ១ ១៦៦ ៨៨២ | ១ ០១៦ ១១២ |
| បំណុលសរុប | | ១ ១៣៨ ៧១៩ | ១ ០៧២ ៩៨៥ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ១០៩ ២៩៤ | ៩៣ ៨៩៧ | ៦៩ ៩៥៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទីបី ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទីបី ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីបី ឆ្នាំ ២០២០ (លានរៀល)** |
| ចំណូលសរុប | | ៥៥ ២៩០ | ៥២ ៥៦៤ | ៤៨ ៦៦៣ |
| ចំណេញមុនបង់ពន្ធ | | ១ ៧២៤ | ៣ ៧១៤ | ៣ ១៦៦ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ៩៣៦ | ២ ២២០ | ១ ៤៦០ |
| ចំណេញ/(ខាត)សរុបលម្អិត | | ៧ ៨២៨ | ៦ ០៣៥ | (៩ ៩៥៧) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទីបី ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** | **ឆ្នាំ ២០២០** |
| អនុបាតសាធនភាព | | ០,៤៩% | ២,៤០% | ៧,៤៣% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | ៦,៣៦% | ៤៩,៩៣% | ២០៣,៨៧% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩៤ | ០,៩០ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៩២ | ០,៨៨ | ០,២៤ |
| | | **ត្រីមាសទីបី ឆ្នាំ ២០២២** | **ត្រីមាសទីបី ឆ្នាំ ២០២១** | **ត្រីមាសទីបី ឆ្នាំ ២០២០** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ០,០៧% | ០,២១% | ០,១៥% |
| | អនុបាតចំណេញធៀបនឹងមូលធន | ០,៨៦% | ២,៥៦% | ១,៩៩% |
| | អនុបាតគម្លាតចំណេញដុល | ១៨,៨៤% | ២១,១៥% | ៣៣,៨៣% |
| | អនុបាតគម្លាតចំណេញភាព | ១,៦៩% | ៤,២២% | ៣,០០% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | ១២,៤៩ | ២៩,៩៨ | ២០,៧៣ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ០,៨៥ | ១,៤២ | ១,៤៧ |

PESTECH

| | | | |
|---|---|---|---|
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន | គ្មាន |

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គិសនីកម្ពុជា។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៣១ ៨៨២ លានរៀល (ឆ្នាំ ២០២១៖ ២០ ៥៥៥ លានរៀល) និង កម្ចីរយៈពេលវែង មានចំនួន ៣៧៩ ៩៨០ លានរៀល គិតត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ (ឆ្នាំ ២០២១៖ ៤០៧ ៨០៦ លានរៀល) ។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



PESTECH

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិក ជាទីរាប់អាន!

យើងមានសេចក្តីសោមនស្សរីករាយណាស់ក្នុងការបង្ហាញជូនលោកអ្នកនូវលទ្ធផលប្រចាំត្រីមាសទី៣ របស់ **ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**។ ភាពប្រសើរឡើងនៃលទ្ធផលប្រតិបត្តិការរបស់យើង វាឆ្លុះបញ្ចាំងបន្ថែមទៀតអំពីភាពអត់ធន់ក្នុងស្ថានភាពងើបឡើងវិញជាទូទៅនៃជំងឺរាលត្បាតនៅក្នុងប្រទេសកម្ពុជា ដែលគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍អាជីវកម្មជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា។

យោងតាមធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានឱ្យដឹងថា សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងអត្រា៥,៣% នៅឆ្នាំ ២០២២ និង អត្រា៦,៥% នៅឆ្នាំ ២០២៣ ដោយសារតែភាពរឹងមាំនៃការនាំចេញទំនិញ និងលំហូរវិនិយោគផ្ទាល់ពីបរទេស។ ការចាក់វ៉ាក់សាំងយ៉ាងទូលំទូលាយប្រឆាំងនឹងវីរុស កូវីត១៩(COVID-19) បានអនុញ្ញាតឱ្យប្រទេសកម្ពុជាបើកព្រំដែនរបស់ខ្លួនឡើងវិញសម្រាប់វិស័យពាណិជ្ជកម្ម និងទេសចរណ៍ ដែលជាកត្តានាំឱ្យមានការរំពឹងទុកផ្នែកសេដ្ឋកិច្ចជាវិជ្ជមានសម្រាប់ឆ្នាំនេះ និងឆ្នាំ២០២៣ នេះបើតាមប្រសាសន៍របស់ លោក អេនតូនី ហ្គីល (Anthony Gill) នាយកស្តីទីនៃ ADB ។ យោងតាមទស្សនៈវិស័យអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ (ADO) ឆ្នាំ២០២២ ទិន្នផលឧស្សាហកម្មត្រូវបានគេរំពឹងទុកថានឹងកើនឡើងអត្រា ៨,១% ក្នុងឆ្នាំ ២០២២ និងអត្រា ៩,១% ក្នុងឆ្នាំ ២០២៣។ កំណើននេះក៏នឹងត្រូវបានជំរុញដោយការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ ក្នុងវិស័យកាត់ដេរ ដូចជាសម្លៀកបំពាក់ ស្បែកជើង និងសម្ភារៈធ្វើដំណើរ ដើម្បីបង្កើនភាពប្រកួតប្រជែងនៅក្នុងផ្នែកនេះ។ ការនាំចេញទំនិញ និងសេវាកម្មត្រូវបានគេព្យាករណ៍ថានឹងកើនឡើងនៅឆ្នាំ ២០២២ និង ២០២៣ ដោយសារមានតម្រូវការផលិតផលកម្ពុជាខ្លាំងពីទីផ្សារខាងក្រៅ អមដោយការគាំទ្រនៃការងើបឡើងវិញនៃសេវាកម្មទេសចរណ៍។ វិស័យសេវាកម្មត្រូវបានគេព្យាករណ៍ថានឹងងើបឡើងវិញនៅក្នុងអត្រា ៤,៨% នៅឆ្នាំនេះ និងបន្តកើនឡើងដល់អត្រា ៦,៨% ក្នុងឆ្នាំ ២០២៣។ ការបើកសេដ្ឋកិច្ចឡើងវិញ និងអត្រានៃការចាក់ថ្នាំនៅក្នុងកម្រិតដ៏ខ្ពស់ នឹងអនុញ្ញាតឱ្យមានការងើបឡើងវិញបន្តិចម្តងៗពាក់ព័ន្ធនឹងវិស័យទេសចរណ៍ដែល គាំទ្រដល់តម្រូវការនៃកន្លែងស្នាក់នៅ អាហារ ការដឹកជញ្ជូន និងសេវាកម្មដោយផ្ទាល់ផ្សេងៗទៀត។ (ប្រភព៖ សេដ្ឋកិច្ចកម្ពុជានឹងកើនឡើងនៅឆ្នាំ២០២២ និងឆ្នាំ២០២៣ — ADB; ព័ត៌មានចេញផ្សាយនៅ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២)។

បរិយាកាសធុរកិច្ចដែលប្រកបដោយអំណោយផលបែបនេះ គួបផ្សំជាមួយនឹងស្ថេរភាពបរិយាកាសសង្គមផ្តល់នូវកម្លាំងចលករ សម្រាប់ការរីកចម្រើន ដែលជំរុញដោយផ្ទាល់ទៅនឹងតម្រូវការយ៉ាងច្រើនសម្រាប់ការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ភាពប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធថាមពល គឺជាគន្លឹះដ៏សំខាន់ក្នុងការជួយគាំទ្រដល់ការរីកចម្រើនជាបន្តបន្ទាប់ នៃវឌ្ឍនភាពឧស្សាហកម្ម និងសង្គមនៅកម្ពុជា។ **PCL** ក្នុងនាមជាក្រុមហ៊ុន នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធថាមពលតែមួយគត់ដែលបានចុះបញ្ជីនៅលើទីផ្សារគោល នៃផ្សារមូលបត្រកម្ពុជា បានដាក់ផែនការរយៈពេលវែងរបស់ខ្លួន ដោយផ្តោតលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថាមពលប្រកបដោយនិរន្តរភាព ដើម្បីបន្តដំណើរនៅលើវិថីនៃការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធថាមពលដោយឥតឈប់ឈរនៅក្នុងប្រទេសកម្ពុជា។

ដើម្បីរក្សាភាពយូរអង្វែងនៃកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍អាជីវកម្មរយៈពេលវែង **PCL** មានការប្តេជ្ញាយ៉ាងមុតមាំ ក្នុងការដើរឆ្ពោះទៅរកការលើកកម្ពស់ចំណេះដឹងផ្នែកលើទេពកោសល្យនៅក្នុងប្រទេសកម្ពុជា បង្កើនសមត្ថភាពវិស្វកម្ម អ្នកជំនាញគូសប្លង់ ការបណ្តុះបណ្តាលក្រុមជំនាញផ្នែកប្រតិបត្តិ និងតំហែទាំ និងលើក

ចិត្ត ក្នុងការធ្វើលទ្ធកម្មជាបន្តបន្ទាប់ នៃឧស្សាហកម្មបច្ចេសទេសជំនាញសំខាន់ៗ ដើម្បីធានាអោយបាននូវការអភិវឌ្ឍន៍សមត្ថភាពដែលមិនចេះរីងស្ងួត សម្រាប់ក្រុមហ៊ុន។

យើង, PESTECH ឆ្លៀតនៅក្នុងឱកាសនេះ សូមធានាទៅដល់ម្ចាស់ភាគហ៊ុន អតិថិជន អ្នកផ្គត់ផ្គង់ និងអ្នកពាក់ព័ន្ធគ្រប់ភាគី ដ៏មានតម្លៃរបស់យើង អំពីការប្តេជ្ញាចិត្តដ៏មោះមុត និងកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់យើង ឆ្ពោះទៅរកការកសាងអភិវឌ្ឍន៍ក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធថាមពលរបស់ប្រទេសកម្ពុជា ដែលតែងតែត្រៀមខ្លួនរួចជាស្រេច ដើម្បីបម្រើតំរូវការ នៅក្នុងតំបន់ទន្លេមេគង្គ។

សូមអរគុណ!

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

Paul Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ៖ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០២២

PESTECH

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

ជូនចំពោះភាគហ៊ុនិក ជាទីរាប់អាន!

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ក្នុងការចែករំលែកជាមួយទាំងអ្នកអស់គ្នានៅទីនេះ អំពីលទ្ធផលប្រចាំត្រីមាសទី៣ ("Q3") សម្រាប់ឆ្នាំហិរញ្ញវត្ថុ ("FY") ២០២២។

ប្រាក់ចំណូលសរុបដែលបានកត់ត្រាក្នុងត្រីមាសទី៣ បានបន្តរក្សាភាពរឹងមាំ គ្រាន់តែទាបជាងត្រីមាសទី២បន្តិចបន្តួចប៉ុននោះ នៅក្នុងទំហំទឹកប្រាក់ចំនួន ៥៥ ២៩០ លានរៀល។ ដំណើរការរលូនទៅមុខនៃគម្រោងខ្សែបណ្តាញបញ្ជូនផ្សេងៗរបស់ក្រុមហ៊ុនយើង បានទ្រទ្រង់ដំណើរការនៃប្រតិបត្តិការអាជីវកម្មនៅក្នុងរបាយការណ៍ត្រីមាសនេះ។ ប្រាក់ចំណេញបានពីប្រតិបត្តិការ ត្រូវបានកត់ត្រាថាមានភាពប្រសើរឡើង ៦% ពីមួយត្រីមាសទៅមួយត្រីមាស នៅពីក្រោយកម្រិតប្រាក់ចំណូលដ៏ស្រដៀងគ្នា ដែលនេះវាបង្ហាញអំពីការផ្លាស់ប្តូរទៅកាន់ដំណាក់កាលកាន់តែរឹងមាំនៃការអនុវត្តគម្រោងទាំងមូល។ ប្រាក់ចំណេញសរុបបន្ទាប់ពីបង់ពន្ធរួចក្នុងត្រីមាសទី៣ ក៏បានកំពុងតែបង្ហាញពីកម្រិតប្រសើរឡើងផងដែរ ដោយមានទំហំទឹកប្រាក់ចំនួន ៩៣៦ លានរៀល ធៀបនឹង ៦៥៦ លានរៀលដែលបានកត់ត្រាក្នុងត្រីមាសមុន។ យើងសង្ឃឹមយ៉ាងមុតមាំថានិន្នាការវិជ្ជមាននេះអាចត្រូវបានបន្តដំណើរទៅមុខជាដរាប ក្នុងការកសាងអាជីវកម្មហេដ្ឋារចនាសម្ព័ន្ធថាមពលប្រកបដោយនិរន្តរភាពក្រោមការគ្រប់គ្រងរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("PCL")។

អនុបាតសាធនភាពនៃក្រុមហ៊ុន ត្រូវបានកត់សម្គាល់ឃើញថាមានភាពប្រសើរក្នុងចំណុចប្រៀបធៀបមួយពោលគឺពីអត្រា ០,៤៥% នៅក្នុងត្រីមាសទី២ ទៅអត្រា ០,៤៩% នៅក្នុងត្រីមាសទី៣។ ទាំង អនុបាតចរន្ត និង អនុបាតចរន្តលឿន បានកើនឡើងបន្តិចបើប្រៀបធៀបទៅនឹងត្រីមាសមុន។ ដូចដែលបានលើកមកបញ្ជាក់ក្នុងអំឡុងត្រីមាសចុងក្រោយនេះ PCL បានបន្តកសាងសមត្ថភាពរបស់ខ្លួនដើម្បីគិតគូររៀបចំតម្រូវការមូលនិធិផ្ទាល់ខ្លួន សម្រាប់គម្រោងជាច្រើនរបស់ខ្លួន ហើយបានចាប់ផ្តើមបង្កើតកំណត់ត្រាតាមដានហិរញ្ញវត្ថុក្នុងស្រុក ដើម្បីរៀបចំខ្លួនក្នុងការចែងអំពីគោលនយោបាយសម្រាប់ការរីកចម្រើនរយៈពេលវែងរបស់ខ្លួនក្នុងនាមជាស្ថាប័នចុះបញ្ជីបោះផ្សាយភាគហ៊ុនមួយនៅក្នុងប្រទេសកម្ពុជា ដែលមានសមត្ថភាពគ្រប់គ្រងតម្រូវការភាគច្រើនទាំងប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់ខ្លួននាពេលអនាគត។ ក្នុងន័យនេះហើយ វាបានជម្រុញអោយអនុបាតលទ្ធភាពបង់ការប្រាក់បានកត់ត្រា នៅក្នុងតម្លៃមួយខ្ពស់ជាង ពោលគឺអត្រា ០,៨៥ នៅក្នុងអំឡុងពេលត្រីមាសទី៣ បើប្រៀបធៀបទៅនឹងអត្រា ០,៧៨ នៅក្នុងត្រីមាសទី២។

យើងក៏បានសង្កេតឃើញកត្តាជំរុញមួយ នៃអនុបាតចំណេញភាពសរុបនៅក្នុងអំឡុងពេលនៃរបាយការណ៍ត្រីមាសនេះដែរ។ អនុបាតចំណេញធៀបនឹងមូលធនត្រូវបានកត់ត្រានៅក្នុងអត្រា ០,៨៦% ធៀបនឹង ០,៦៥% ហើយចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ បានកើនឡើងច្រើនជាង ៤២% ដល់ ១២,៩៩ ពាន់រៀលក្នុងត្រីមាសទី៣។

គណៈគ្រប់គ្រងក្រុមហ៊ុន សូមថ្លែងអំណរគុណដ៏ជាលជ្រៅចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារ PCL ប្រចាំនៅប្រទេសកម្ពុជា ដែលបានផ្តល់ការគាំទ្រឥតឈប់ឈរមកកាន់ក្រុមហ៊ុន ជាមួយនឹងអាកប្បកិរិយាការងារប្រកបដោយភាពវិជ្ជមាន ភាពជឿជាក់ និងស្មារតីនៃមិត្តភាព។ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងខ្លាំងផងដែរ ចំពោះអតិថិជន ជាពិសេសអគ្គិសនីកម្ពុជា ដែលជឿជាក់មកលើយើងខ្ញុំក្នុងការនាំយកមកនូវគម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលសំខាន់ៗ ក្នុងការគាំទ្រដល់ការរីកចម្រើន និងការអភិវឌ្ឍន៍របស់ប្រទេសជាតិ។

PESTECH

ក្នុងទិដ្ឋភាពរយៈពេលវែង ជាមួយនឹងការជឿជាក់យ៉ាងមុតមាំ គណៈគ្រប់គ្រងក្រុមហ៊ុនមានគោលដៅ សំដៅការរុករក និងទទួលយកគំនិតផ្ដួចផ្ដើមថ្មីៗ ដើម្បីពង្រីកវិសាលភាពអាជីវកម្មរបស់ PCL បន្តិចម្ដងៗ ក្នុងគោលបំណងបើកអោយមានវិធីសាស្ត្រថ្មីៗ ក្នុងការអភិវឌ្ឍន៍ដែលសមស្របទៅនឹងចក្ខុវិស័យរបស់ក្រុមហ៊ុន PESTECH Group ក្នុងការរក្សាភាពរីកចម្រើនប្រកបដោយនិរន្តរភាព។ ភាគហ៊ុននិកនៃ PCL នឹងអាចមើលឃើញទៅនឹង ការពាក់ព័ន្ធនៃភាពរីករីកចម្រើនរបស់ PCL ទៅក្នុងផ្នែកដែលទាក់ទងនឹងចរន្តសេដ្ឋកិច្ចរាងជារង្វង់ តួយ៉ាង ការកែប្រែកាកសំណល់ទៅជាផលិតផល និងការកែច្នៃកាកសំណល់ដែលអាចកកើតឡើងវិញបាន។

ក្នុងនាមជានាយកប្រតិបត្តិនៃ PCL ខ្ញុំសូមថ្លែងអំណរគុណចំពោះទំនុកចិត្តរបស់អស់លោកអ្នកមកលើក្រុមហ៊ុនរបស់យើងខ្ញុំ ហើយខ្ញុំសូមផ្ដល់ការសន្យារបស់ខ្ញុំក្នុងការខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីផ្ដល់លទ្ធផលវិជ្ជមានដល់ម្ចាស់ភាគហ៊ុនទាំងអស់គ្នា។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា ប៉េសធិច (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

Han Fatt Juan

ប្រធាននាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០២២

PESTECH

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i
សមាសភាពក្រុមប្រឹក្សាភិបាល ........ ii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ iii
សេចក្តីថ្លែងរបស់នាយប្រតិបត្តិ ........ iv

**ផ្នែកទី ១-ព័ត៌មានទូទៅនៃក្រុមហ៊ុនចុះបញ្ជី**

ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី
ខ. ប្រភេទអាជីវកម្ម
គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច
ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ**

**ផ្នែកទី ៤ - កិច្ចពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ
ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ
គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល
ឃ.ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ
ង. ផលប៉ះពាល់នៃអតិផរណា
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងសាច់ប្រាក់របស់រាជរដ្ឋាភិបាល

**ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន (ប្រសិនបើមាន)**

ហត្ថលេខារបស់អភិបាលក្រុមហ៊ុន

## ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន

### ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **ផេសថិក (ខេមបូឌា)ម.ក**

ជាអក្សរឡាតាំង៖ **PESTECH (Cambodia) PLC**

លេខកូដស្គាល់៖ **PEPC**

អាសយដ្ឋាន៖ **ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ទី II ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា ។ នៅក្នុងកិច្ចប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុន ដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ក្នុងនោះភាគហ៊ុននិករបស់ក្រុមហ៊ុន បានសម្រេចធ្វើការផ្លាស់ប្តូរអាសយដ្ឋានក្រុមហ៊ុន ទៅ ជាន់ទី១០, អគារលេខ២៥, ផ្លូវម៉ៅសេទុង, ភូមិ៩, សង្កាត់បឹងកេងកង១, ខណ្ឌបឹងកេងកង, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា ហើយបច្ចុប្បន្នសំណើរស្នើសុំនេះ កំពុងរង់ចាំការយល់ព្រម ពីក្រសួងមហាផ្ទៃ។**

លេខទូរសព្ទ៖ **+៨៥៥ ២៣ ៨៨២ ១០៥** ទូរសារ៖ **+៨៥៥ ២៣ ៨៨២ ១០៦**

គេហទំព័រ៖ www.pestech.com.kh អ៊ីមែល៖ **info@pestech.com.my**

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ **00000៩៥៧** កាលបរិច្ឆេទ៖ **ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១០**

លេខអាជ្ញាប័ណ្ណអាជីវកម្ម៖ **៣២៦ Brk.DnS/ASN** ចេញដោយ៖ **MLMUPC**

កាលបរិច្ឆេទ៖ **ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៨**

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ៖ **១៧១/២០ គ.ម.គ / ស.ស.រ.**

គ.ម.ក កាលបរិច្ឆេទ៖ **២២ ខែកក្កដា ឆ្នាំ២០២០**

អ្នកតំណាងរបស់ក្រុមហ៊ុន៖ **Paul Lim Pay Chuan**

### ខ. ប្រភេទអាជីវកម្ម

PCL ចូលរួមជាចម្បងនៅក្នុងការផ្តល់ដំណោះស្រាយផ្នែកវិស្វកម្ម និងបច្ចេកទេសនៃប្រព័ន្ធអគ្គិសនីគ្រប់ជ្រុងជ្រោយសម្រាប់៖

- ការរចនាប្លង់ ការធ្វើលទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឲ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គិសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដី សម្រាប់បញ្ជូន និងចែកចាយអគ្គិសនីផងដែរ
- ការដំណើរការ និងថែទាំ ("O&M") ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយ៍ និង
- ការធ្វើជំនួញសមាសធាតុ និងបរិក្ខារប្រព័ន្ធអគ្គិសនីដែលមានពាណិជ្ជសញ្ញាជារបស់ខ្លួនឯង និងមិនមែនជារបស់ខ្លួនឯង។

### គ.ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

ស្ថិតក្រោមការពិនិត្យ មិនមានព្រឹត្តិការណ៍សំខាន់ នៅក្នុងកំឡុងពេលឆមាសនេះទេ ។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការអាជីវកម្ម

## ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និង អនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាស ដែលមានទឹកប្រាក់ចំនួន ៥២ ០៧៣ លានរៀល (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៤៩ ៣៧៨ លានរៀល) ដែលស្មើនឹងប្រមាណ ៩៤,២% (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៩៣,៩%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M")ដែលបានរួមចំណែកប្រមាណចំនួន ៣ ២១៧ លានរៀល ឬ ៥,៨% នៃចំណូលសរុប (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៣ ១៨៦ លានរៀល ឬ ៦,១%)។ ក្នុងអំឡុងត្រីមាស កិច្ចព្រមព្រៀង("O&M") សម្រាប់គម្រោង នៅក្រុងបាវិត បានចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ ២០២២។ ដូចនេះប្រាក់ចំណូល ("O&M") គិតជាដុល្លារអាមេរិក និងត្រូវបានកត់ត្រាត្រឹម ចំនួន ៧៩៦ ០០០ ដុល្លារអាមេរិច ជារៀងរាល់ត្រីមាស។

ក្នុងកំឡុងត្រីមាសនេះ យើងបានទទួលស្គាល់ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យាមានចំនួន ២ ៧៩៨ លានរៀល (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ២០២១៖ ១ ២៨៦ លានរៀល)។ ចំណូលហិរញ្ញប្បទានបានមកពីការអនុលោមតាម ស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS") ១៥ សម្រាប់គម្រោងមួយចំនួនរបស់យើង ហើយវាគឺជាផ្នែកមួយនៃប្រាក់ចំណូលសរុបរបស់យើងនៅក្នុងសម្ព័ន្ធ។ ការកើនឡើងនៃប្រាក់ចំណូលហិរញ្ញប្បទានក្នុងត្រីមាសបច្ចុប្បន្ន ដែលមានទឹកប្រាក់ចំនួន ១ ៥១២ លានរៀល ឬ ១,១៨% គឺដោយសារតែមានការទទួលស្គាល់ចំណូលហិរញ្ញប្បទាន នៅគម្រោងក្រុងព្រះសីហានុ នៅខែ មីនា ឆ្នាំ ២០២១។

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទីបី ឆ្នាំ ២០២២ | | ត្រីមាសទីបី ឆ្នាំ ២០២១ | | ត្រីមាសទីបី ឆ្នាំ ២០២០ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC) កិច្ចសន្យាសម្រាប់បណ្តាញអគ្គីសនីនិងអនុស្ថានីយ៍ | ៥២ ០៧៣ | ៩៤,២ | ៤៩ ៣៧៨ | ៩៣,៩ | ៤៦ ៣៨៣ | ៩៥,៣ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៣ ២១៧ | ៥,៨ | ៣ ១៨៦ | ៦,១ | ២ ២៨០ | ៤,៧ |

PESTECH

| | | | | | | |
|---|---|---|---|---|---|---|
| **ប្រាក់ចំណូលសរុប** | **៥៥ ២៩០** | **១០០,០** | **៥២ ៥៦៤** | **១០០,០** | **៨៨ ៦៦៣** | **១០០,០** |
| ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | ២ ៧៩៨ | ១០០,០ | ១ ២៨៦ | ១០០,០ | គ្មាន | គ្មាន |
| **ប្រាក់ចំណូលសរុប** | **៥៨ ០៨៨** | **១០០,០** | **៥៣ ៨៥០** | **១០០,០** | **៨៨ ៦៦៣** | **១០០,០** |

## ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

## ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (“MD&A”)

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ៥៥ ២៩០ លានរៀល ដោយកើនឡើងចំនួន ២ ៧២៦ លានរៀល ឬ ៥,២% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៥២ ៥៦៤ លានរៀល ។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។

២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ (“EPCC”) សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលសម្រាប់របាយការណ៍ប្រចាំត្រីមាស ដែលមានទឹកប្រាក់ចំនួន ៥២ ០៧៣ លានរៀល (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៤៩ ៣៧៨ លានរៀល) ដែលស្មើនឹងប្រមាណ ៩៤,២% (ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៩៣,៩%) នៃចំណូលសរុប ។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសេវាថែទាំ(“O&M”)ដែលស្មើនឹងប្រមាណ ៣ ២១៧ លានរៀល ឬ ៥,៨%នៃចំណូលសរុប(ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ២០២១៖ ៣ ១៨៦ លានរៀលឬ៦,១%) ក្នុងអំឡុងត្រីមាស (“O&M”) សម្រាប់គម្រោង ថាមពលដើរដោយពន្លឺព្រះអាទិត្យ បានចាប់ផ្តើមនៅខែកុម្ភៈ ឆ្នាំ ២០២២។ ដូចនេះ ប្រាក់ចំណូល(“O&M”) គិតជាដុល្លារអាមេរិក និងត្រូវបានកត់ត្រាត្រឹមចំនួន ៧៩៦ ០០០ ដុល្លារអាមេរិច ជារៀងរាល់ត្រីមាស។

៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ១៨,៨% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន មានចំនួន ២១,២% ដោយថយចុះចំនួន ២,៤%។ ប្រាក់ចំណេញខ្ពស់ជាងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដែលបណ្តាលមកពីការកែប្រែ នៃចំណូលគម្រោងសំណង់ នៅតាតៃ ដែលជាលទ្ធផលបានមកពីការពន្យារពេល។ ទោះបីជាយ៉ាងណាក៏ដោយ បម្រែបម្រួលនៃចំណេញដុលគឺអាស្រ័យទៅលើប្រាក់ចំណេញដាច់ដោយឡែកនៃគម្រោងជាក់លាក់នីមួយៗដែលបានប្រតិបត្តិក្នុងអំឡុងពេលនោះ ។ សរុបមកចំណេញដុលសម្រាប់រយៈពេលបច្ចុប្បន្នគឺស្ថិតនៅក្នុងការរំពឹងទុករបស់សម្ព័ន្ធក្រុមហ៊ុន។

៤. ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្ន ក្រោមការត្រួតពិនិត្យឡើងវិញ ដែលត្រូវបានកត់ត្រាត្រឹមចំនួន ១ ៧២៤លានរៀល បើប្រៀបធៀបទៅនឹងការចំណេញមុនពេលបង់ពន្ធមានចំនួន ៣ ៧១៤ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះមានចំនួន ១ ៩៩០ លានរៀល ឬ ៥៣,៦% ។ ប្រាក់ចំណេញមុនបង់ពន្ធទាប

PESTECH

ជាងក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញគឺបណ្តាលមកពីប្រាក់ចំណេញដុលទាបជាងនិងថ្លៃដើមហិរញ្ញវត្ថុខ្ពស់ជាងបើប្រៀបធៀបទៅនិងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ។

៥. ការវិភាគចំណេញក្នុងការិយបរិច្ឆេទ

លទ្ធផលនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ៩៣៦ លានរៀល បើប្រៀបធៀបទៅនឹងចំណេញក្រោយដកពន្ធមានចំនួន ២ ២២០ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះមានចំនួន ១ ២៨៤ លានរៀល ឬ ៥៧,៨% ។

**ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ**

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយ ដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

**គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល**

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ៥៥ ២៩០ លានរៀល ដោយកើនឡើងចំនួន ២ ៧២៦ លានរៀល ឬ ៥,២% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៥២ ៥៦៤ លានរៀល ។ បម្រែបម្រួលនៃចំណូលសរុបបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ សម្រាប់រយៈពេល៩ខែនៃរយៈពេលហិរញ្ញវត្ថុ ដែលស្ថិតក្រោមការត្រួតពិនិត្យឡើងវិញ ចំណូលសរុបដែលបានកត់ត្រាមានចំនួន ១៨៧ ៦៥១ លានរៀលដោយកើនឡើងចំនួន ២៤ ៧៨៩ លានរៀល ឬ ១៥,២% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនចំនួន ១៦២ ៨៦២លានរៀល។ បម្រែបម្រួលនៃចំណូលសរុបសម្រាប់រយៈពេល៣ខែនៃត្រីមាស និងរយៈពេល៩ខែ ភាគច្រើនបានមកពីដំណាក់កាលផ្សេងៗនៃការអនុវត្តកិច្ចសន្យាដែលមានស្រាប់ ។

**ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ**

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

**ង. ផលប៉ះពាល់នៃអតិផរណា**

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ៩% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៤,៧០% (គិតត្រឹមថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២២ ប្រភព៖ *តម្លៃថាមពលត្រូវបានកំណត់បង្កើនល្បឿននៃអតិផរណាអាចដល់៤,៧% នៅឆ្នាំ ២០២២)* ដែលបានបង្កផលប៉ះពាល់ប្រហែល ០,៩៤% ប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង ។ រាល់ចំណាយប្រតិបត្តិការផ្សេងៗទាំងអស់ មានសមាសធាតុចំណាយថេរ នៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល ។ ក្រៅពីការលើកឡើងខាងលើនេះពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

**ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល**

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះនោះទេ។

PESTECH

## ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

## **ហត្ថលេខារបស់អភិបាលក្រុមហ៊ុន**

(នឹងត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល រឺយ៉ាងតិចដោយប្រធានប្រតិបត្តិចំនួនពីររូប)

កាលបរិច្ឆេទ៖ ០៦,ឧសភា,២០២២

បានអាន និងឯកភាព៖

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ហត្ថលេខា

ឈ្មោះ៖ Paul Lim Pay Chuan

មុខតំណែង៖ **ប្រធានក្រុមប្រឹក្សាភិបាល**